00338900

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / JUN / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E77

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / JUNE / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ:០០១/១៨ កក្កដា ឆ្នាំ ២០០៧-អវតក/អជសដ
Case File/Dossier N° 001/18-07-2007-ECCC/TC

| | |
|---|---|
| ចំពោះមុខ | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ | ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៩ |
| ប្រភេទឯកសារ | សាធារណៈ |

---

## ដីកាកំណត់ថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែបន្ទាប់ (ចាប់ពីថ្ងៃទី ០៦ ខែ កក្កដា ដល់ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៩)

---

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គីមសួន
យុង ផានិត

Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX
MARIE-PAULE CANIZARES

អង្គជំនុំជម្រះសាលាដំបូង * TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE * E C C C E T C

គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN

Philippe CANNONE
ទី ស្រ៊ីនណា
Elizabeth RABESANDRATANA
Karim KHAN

យើងចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ អនុលោមតាម "សេចក្តីសម្រេចលើបណ្តឹង ឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលចោទប្រកាន់លើជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច" ដែលប្រកាសផ្ទាល់មាត់ដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ និង បានដាក់សេចក្តីសម្រេចជាភាសាខ្មែរ នៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០០៨[1]។

**បានឃើញ** ដីកាសម្រេចកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តី និងថ្ងៃជំនុំជម្រះសម្រាប់ រយៈពេលបីខែដំបូងរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០៩[2]។

**បានកត់សម្គាល់ឃើញថា** កិច្ចប្រជុំពេញអង្គនឹងចាប់ផ្តើមធ្វើពីថ្ងៃទី ០៧ ដល់ថ្ងៃទី ១១ ខែកញ្ញា ២០០៩។

**បានកត់សម្គាល់ឃើញថា** ថ្ងៃ១៨ ដល់ថ្ងៃ ២១ និងថ្ងៃ ២៤ ខែកញ្ញា ឆ្នាំ ២០០៩ ជាថ្ងៃឈប់សម្រាក សម្រាប់ អ.វ.ត.ក។

**ដោយពិចារណាលើ** សវនាការទាំងឡាយរបស់អង្គបុរេជំនុំជម្រះនឹងត្រូវបានកំណត់ដាក់នៅថ្ងៃពុធ ទី២៩ ដល់ថ្ងៃសុក្រ ទី៣១ ខែកក្កដា ឆ្នាំ ២០០៩ ។

**ដោយពិចារណាអំពី** ភាពចាំបាច់ក្នុងការធានាអោយបាននូវសវនាការមួយប្រកបទៅដោយភាពយុត្តិធម៌។

**ដោយពិចារណាអំពី** ភាពចាំបាច់ក្នុងការជូនដំណឹងឲ្យបានគ្រប់គ្រាន់អំពីកាលបរិច្ឆេទសវនាការដល់ភាគី ទាំងអស់ ។

---

[1] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច" ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/42)។

[2] ដីកាសម្រេចកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តី និងថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែដំបូង ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០៩ (ឯកសារ E15)។

00338902

E77

001/18-07-2007-ECCC/TC

# ហេតុដូច្នេះ

**សម្រេចថា** សវនាការលើអង្គសេចក្ដីចំពោះសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសជ ទាក់ទងនឹងជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** នឹងបន្តធ្វើចាប់ពីថ្ងៃច័ន្ទ ទី០៦ ខែ កក្កដា ឆ្នាំ ២០០៩ ដល់ថ្ងៃព្រហស្បតិ៍ ទី ០១ ខែ តុលា ២០០៩ នៅម៉ោង ៩ ព្រឹក រៀងរាល់សប្ដាហ៍នៅសាលសវនាការនៃ អ.វ.ត.ក លើកលែងតែមានការសម្រេចផ្សេងពីនេះ និងចំពោះថ្ងៃដែលចង្អុលបង្ហាញខាងក្រោមនេះ។ ចំនួនថ្ងៃធ្វើសវនាការមានការប្រែប្រួលរវាងសប្ដាហ៍ដែលមានការធ្វើសវនាការបួនថ្ងៃគឺ ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃព្រហស្បតិ៍ និងសប្ដាហ៍ដែលមានការធ្វើសវនាការបីថ្ងៃ គឺពីថ្ងៃចន្ទ ដល់ថ្ងៃពុធ រៀងរាល់សប្ដាហ៍ទីបី ដោយផ្ដើមធ្វើបួនថ្ងៃចាប់ពីសប្ដាហ៍ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩។ ការធ្វើសវនាការបែបនេះនឹងបន្តធ្វើ រហូតដល់ចប់កាលវិភាគសវនាការ លើកលែងតែអង្គជំនុំជម្រះសម្រេចផ្សេងពីនេះ។

**សម្រេច** មិនធ្វើសវនាការនៅថ្ងៃពុធ ទី២៩ ថ្ងៃព្រហស្បតិ៍ ទី៣០ ខែកក្កដា និងចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០៩[3]។

**សូមបញ្ជាក់ថា** កាលវិភាគសវនាការបន្តបន្ទាប់ទៀតនឹងត្រូវកំណត់នៅពេលក្រោយក្នុងរយៈពេលសមស្រប។

**សម្រេចបន្ថែមថា** សេចក្ដីសម្រេចនេះត្រូវជូនដំណឹងទៅភាគីទាំងអស់ និងទៅការិយាល័យរដ្ឋបាល ហើយនឹងត្រូវចុះផ្សាយនៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក.។

ភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**

---

[3] ថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការជំនុំជម្រះគឺ៖ ថ្ងៃទី ០៦ ដល់ថ្ងៃទី ០៩ ខែ កក្កដា, ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កក្កដា, ថ្ងៃទី ២០ ដល់ថ្ងៃទី ២២ ខែកក្កដា, ថ្ងៃទី ២៧ដល់ថ្ងៃទី ២៨ ខែ កក្កដា, ថ្ងៃទី ០៣ ដល់ថ្ងៃទី ០៦ ខែសីហា, ថ្ងៃទី ១០ ដល់ថ្ងៃទី ១២ ខែសីហា, ថ្ងៃទី ១៧ ដល់ថ្ងៃទី ២០ ខែសីហា, ថ្ងៃទី ២៤ ដល់ថ្ងៃទី ២៧ ខែសីហា, ថ្ងៃទី ៣១ ខែសីហា ដល់ថ្ងៃទី ០២ ខែកញ្ញា, ថ្ងៃទី ១៤ ដល់ថ្ងៃទី ១៧ ខែកញ្ញា, ថ្ងៃទី ២២ ដល់ថ្ងៃទី ២៣ ខែកញ្ញា និងថ្ងៃទី ២៨ ខែកញ្ញា ដល់ថ្ងៃទី ០១ តុលា។